អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន
## របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង

ចាប់តាំងពីពេលចូលបំពេញមុខងារនៅ អ.វ.ត.ក មក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានខិតខំប្រឹងប្រែងអស់កម្លាំងកាយចិត្ត រហូតដល់ដំណាក់កាលចុងក្រោយ ដើម្បីបន្តការស៊ើបអង្កេតលើសំណុំរឿង ០០៣ និង០០៤ ដ៏ចម្រូងចម្រាស ដោយគោរពច្បាប់ និងគោរពដល់ជនរងគ្រោះ។ ក្រៅពីការចុះស៊ើបអង្កេតដល់កន្លែង ជនសង្ស័យត្រូវបានជូនដំណឹងអំពីសិទ្ធិរបស់ខ្លួន និងទទួលបានការអនុញ្ញាតឲ្យចូលមើលសំណុំរឿង។ តាមរយៈសេចក្តីសម្រេចស្តីពីសមត្ថកិច្ចរបស់ អ.វ.ត.ក ក្នុងការជំនុំជម្រះសំណុំរឿង ០០៣ អង្គហេតុកំពុងស៊ើបសួរត្រូវបានជូនដំណឹងជាសាធារណៈ ដើម្បីអនុញ្ញាតឲ្យជនរងគ្រោះដឹង និងប្រើប្រាស់សិទ្ធិរបស់ខ្លួន។

ច្បាស់ណាស់ ដោយសារតែហេតុផលនយោបាយ និងហិរញ្ញវត្ថុ ជាជាងហេតុផលគតិយុត្តិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ដែលបុព្វសិទ្ធិត្រូវបានសហចៅក្រមស៊ើបអង្កេតជាតិជំទាស់ជាប្រចាំដោយគ្មានសំអាងហេតុសមស្របតាមផ្លូវច្បាប់ ត្រូវបានរារាំងយ៉ាងធ្ងន់ធ្ងរក្នុងការបំពេញមុខងាររបស់ខ្លួនដោយស្របច្បាប់ ក្នុងបរិយាកាសពោរពេញដោយអរិភាព ជាហេតុធ្វើឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានសម្រេចចិត្តដាក់ពាក្យលាឈប់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។

ក្រោយពេលបញ្ចប់ការស៊ើបអង្កេតផ្ទៃក្នុង ពីបទរំលោភវិធាន ៣៥ នៃវិធានផ្ទៃក្នុង អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងមានហេតុផលក្នុងការជឿជាក់ថា បុគ្គលជាច្រើនរូប ដែលកំពុង ឬបានបំពេញការងារនៅ អ.វ.ត.ក បានជ្រៀតជ្រែកក្នុងការស៊ើបអង្កេតលើសំណុំរឿង ០០៤។ ដូច្នេះ នៅថ្ងៃនោះ សហចៅក្រម ស៊ើបអង្កេតអន្តរជាតិបម្រុងបានប្តឹងបរិហាររឿងហេតុទាំងនេះ ទៅអាជ្ញាធរព្រហ្មទណ្ឌនៃព្រះរា

ជាណាចក្រកម្ពុជា។ ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងយល់ឃើញថា តួនាទីរបស់សហចៅក្រម ស៊ើបអង្កេតជាតិ ដូចបានលើកឡើងនៅក្នុងកំណត់សម្គាល់ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ គឺជាការរារាំងយ៉ាងធ្ងន់ធ្ងរដល់ការដឹកនាំកិច្ចស៊ើបសួរលើសំណុំរឿង ០០៣ និង ០០៤ ហើយសហចៅក្រម ស៊ើបអង្កេត អន្តរជាតិបម្រុងបានប្ដឹងទៅឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងសូមធ្វើការអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិ ឲ្យប្រកាន់ជំហរច្បាស់លាស់ដូចគ្នាចំពោះជោគវាសនានៃសំណុំរឿង ០០៣ និង ០០៤ ដើម្បីផ្ដល់ភាពរុងរឿង និងសេចក្ដីថ្លៃថ្នូរ ដែល អ.វ.ត.ក និងតុលាការអន្តរ-ជាតិ ស័ក្ដិសមនឹងទទួលបាន។



Original EN: 00803892-00803892